**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ស្ថានការណ៍ការពារ ជំងឺរលាកសួត មិនស្គាល់អត្តសញ្ញាណ ( មិនដឹងប្រភព ឬមូលហេតុ )

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ ជាពិសេសអ្នកដំណើរដែលមានគម្រោងធ្វើដំណើរទៅ ឬត្រលប់មកពីទីក្រុងវូហាន ខេត្តហ៊ូប៉េ សាធារណរដ្ឋប្រជាមានិតចិន អំពីជំងឺរលាកសួតមិនស្គាល់អត្តសញ្ញាណ នូវព័ត៌មានសំខាន់ៗ និងវិធានការប្រុងប្រយ័ត្នផ្ទាល់ខ្លួន ដែលគួរយល់ដឹង ដូចតទៅ៖

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមបញ្ជាក់ថា មិនទាន់មានករណីជំងឺប្រភេទខាងលើនេះនៅប្រទេសកម្ពុជានៅឡើយ ហើយក្រសួងកំពុងតែតាមដានដោយយកចិត្តទុកដាក់បំផុតនូវស្ថានភាពនៃការកើតមានករណីជំងឺរលាកសួតមិនស្គាល់អត្តសញ្ញាណ ក្រោយពីបានទទួលព័ត៌មានពីអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា ដែលករណីជំងឺរលាកសួតប្រភេទនេះ ត្រូវបានរកឃើញ និងបានរាយការណ៍ដំបូងនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ នៅទីក្រុងវូហាន ខេត្តហ៊ូប៉េ សាធារណរដ្ឋប្រជាមានិតចិន ជាមួយរោគសញ្ញាភាគច្រើន គឺក្តៅខ្លួន មានអ្នកជំងឺពីរ-បីនាក់មានរោគសញ្ញាហត់ ហើយថតកាំរស្មីអិចបង្ហាញថាមានដំបៅសួតសងខាង។ លទ្ធផលទទួលបានពីមន្ទីរពិសោធន៍ បានបញ្ជាក់ថា ជំងឺដែលកំពុងកើតឡើងនេះ មិនមែនជាជំងឺ SARS ឬជំងឺផ្តាសាយបក្សី ឬជំងឺផ្តាសាយបង្ករដោយវីរុសអាដេណូ (adenovirus) ឬជំងឺ MERS ឬក៏ជំងឺផ្លូវដង្ហើមដទៃទៀតនោះឡើយ។ ការអង្កេតស្រាវជ្រាវដោយមន្ទីរពិសោធន៍នៃប្រទេសចិន កំពុងបន្តធ្វើទៀតដើម្បីស្វែងរកអត្តសញ្ញាណនៃជំងឺរលាកសួតចម្លែកនេះ។ តាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ក៏បានបង្ហាញផងដែរថា រហូតមកដល់ពេលនេះ មិនទាន់មានភស្តុតាងណាមួយបញ្ជាក់ពីការឆ្លងពីមនុស្សទៅមនុស្សនៅឡើយ ហើយក៏មិនទាន់មានការចម្លងទៅបុគ្គលិកសុខាភិបាលនោះដែរ។ នៅពេលនេះ អ្នកជំនាញកំពុងតែប្រមូលព័ត៌មានអេពីដេមីសាស្ត្រ និងមន្ទីរពិសោធន៍បន្ថែមទៀត ដើម្បីកំណត់រកអត្តសញ្ញាណនៃវីរុស។

គិតត្រឹមម៉ោង ៨ ព្រឹកនាថ្ងៃទី ៥ ខែមករា ឆ្នាំ ២០២០ ខេត្តវូហាន បានរាយការណ៍ថា មានអ្នកជំងឺសរុបចំនួន ៥៩ នាក់ ដែលមានជំងឺរលាកសួតដោយសារវីរុសដែលមិនស្គាល់អត្តសញ្ញាណ ក្នុងនោះមាន ៧ នាក់មានជំងឺធ្ងន់ធ្ងរ ហើយអ្នកជំងឺដទៃទៀតមានស្ថានភាពធ្ងន់ធ្ងរ។ នាពេលបច្ចុប្បន្ន អ្នកជំងឺទាំងអស់កំពុងទទួលការព្យាបាលដោយដាក់ឲ្យនៅដាច់ដោយឡែកពីគេ ហើយគ្មានអ្នកស្លាប់ទេ។ ក្នុងចំណោមអ្នកជំងឺ ៥៩ នាក់ អ្នកជំងឺដំបូងបានចាប់ផ្តើមឈឺនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៩ និងអ្នកជំងឺចុងក្រោយបង្អស់បានចាប់ផ្តើមឈឺនៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៩។ អ្នកប៉ះពាល់ជាមួយអ្នកជំងឺមាន ១៦៣នាក់ ដែលកំពុងតាមដានសម្រាប់ការសង្កេតផ្នែកវេជ្ជសាស្ត្របន្ត។ ការធ្វើអង្កេតអេពីដេមីសាស្ត្របានបង្ហាញថា អ្នកជំងឺខ្លះជាឈ្មួញកណ្តាល ឬជាអ្នកលក់ផ្ទាល់(ម្ចាស់ផ្ទាល់) ឬអ្នកបំរើសេវាផ្ទាល់ នៅផ្សារលក់គ្រឿងសមុទ្រហួណាន់ដែលជាទីផ្សារលក់គ្រឿងសមុទ្របោះដុំធំជាងគេក្នុងខេត្តនេះ ដែលមានតូបលក់គ្រឿងសមុទ្រ ជាង៦០០តូប និងមានអ្នកបំរើការងារចំនួន១៥០០នាក់ មានសត្វព្រៃក៏ត្រូវបានដាក់លក់នៅផ្នែកខ្លះនៃទីផ្សារនេះដែរ។

បច្ចុប្បន្ននេះ ក្រសួងសុខាភិបាលកម្ពុជា កំពុងបន្តតាមដានស្ថានភាពនៃជំងឺនេះនៅក្នុងតំបន់ ដោយមានការប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា និងសូមជម្រាបជូនផងដែរថា នៅប្រទេសកម្ពុជាមិនទាន់មានករណីជំងឺបែបនេះកើតមាននោះទេ។ ក្នុងគោលបំណងការពារទុកជាមុន នូវការកើតឡើងជាយថាហេតុនៃជំងឺរលាកសួតមិនស្គាល់អត្តសញ្ញាណនេះ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមអំពាវនាវសូមឲ្យអ្នកធ្វើដំណើរដែលទៅ ឬ វិលត្រឡប់មកពីទីក្រុងវូហាន ខេត្តហ៊ូប៉េ សាធារណរដ្ឋប្រជាមានិតចិន ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ដោយត្រូវចេះថែរក្សាសុខភាពផ្ទាល់ខ្លួន ដោយអនុវត្តនូវវិធានការណ៍សាមញ្ញៗមានដូចខាងក្រោមនេះ។ ប្រសិនបើលោកអ្នក មានរោគសញ្ញាដូចជា គ្រុនក្តៅ ក្អក និងពិបាកដកដង្ហើម ទាំងក្នុងអំឡុងពេល ធ្វើដំណើរ ឬបន្ទាប់ពីការវិលត្រឡប់មកពីកន្លែងដែលបានជម្រាបខាងលើ សូមទៅជួបវេជ្ជបណ្ឌិត (នៅគ្រឹះស្ថានសុខាភិបាលសាធារណៈដែលនៅជិតបំផុតភ្លាម) និងប្រាប់ពត៌មានដល់គ្រូពេទ្យអំពីប្រវត្តិនៃការធ្វើដំណើរ និងរោគសញ្ញារបស់លោកអ្នក។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា៖ *ខ្ញុំសូមប្រកាសធ្វើការក្រើនរំលឹក ជូនដល់ប្រជាពលរដ្ឋទាំងអស់ ឲ្យមានការប្រុងប្រយ័ត្នខ្ពស់លើការបង្ការការចម្លងជំងឺរលាកសួតដែលមិនស្គាល់អត្តសញ្ញាណ ដែលអាចកើតមានជាយថាហេតុ ដោយអនុវត្តនូវវិធានការណ៍ដូចតទៅ ៖*

១. ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកមានជំងឺផ្លូវដង្ហើមស្រួច។

២. លាងដៃឲ្យបានញឹកញាប់ (ជាមួយសាប៊ូនិងទឹកស្អាត) ជាពិសេសបន្ទាប់ពីប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺឬបរិស្ថានជុំវិញគាត់។

៣. ជៀសវាងប៉ះពាល់ជិតស្និទ្ធ ឬទៅទីផ្សារលក់គ្រឿងសមុទ្រហួណាន ឬទីផ្សារ ឬកសិដ្ឋានដែលមានសត្វរស់ ឬសត្វព្រៃ ឬកន្លែងដែលគេដឹងថាមានវីរុសកំពុងចរាចរ។ ចាំបាច់ ត្រូវលាងដៃឲ្យបានទៀងទាត់មុនពេល និងបន្ទាប់ពីការប៉ះពាល់សត្វ ឬវត្ថុផ្សេងៗ ដែលអាចជាប្រភពចម្លងរោគ។

៤. ប្រកាន់ខ្ជាប់នូវការអនុវត្តន៍អនាម័យស្អាត និងសុវត្ថិភាពម្ហូបអាហារល្អ ដូចជា ពិសារអាហារដែលចំអិនឆ្អិនល្អ ។

៥. អ្នកមានរោគសញ្ញាជំងឺផ្លូវដង្ហើមស្រួច ត្រូវខ្ទប់មាត់និងច្រមុះនៅពេលក្អកឬកណ្តាស់ ដោយកន្សែង ក្រម៉ា ឬក្រដាស។

៧. ត្រូវប្រកាន់យកនូវអនាម័យដៃស្អាត និងអនាម័យផ្លូវដង្ហើម (ខ្ទប់មាត់និងច្រមុះនៅពេលក្អកឬកណ្តាស់, លាងដៃបន្ទាប់ពីមានប៉ះជាមួយទឹករំអិលពីផ្លូវដកដង្ហើម និងរក្សាចម្ងាយច្រើនជាង១ម៉ែត្រជាមួយបុគ្គលដែលមានរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវ ជាដើម)។

ទោះបីជានៅប្រទេសកម្ពុជាមិនទាន់មានករណីជំងឺនេះនៅឡើយ ប៉ុន្តែ ក្រសួងសុខាភិបាលបានដាក់ម៉ាស៊ីនស្កេនកំដៅនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រុងព្រះសីហនុ និងសៀមរាប និងស្រាវជ្រាវរកករណីសង្ស័យដោយក្រុមចត្តាឡីស័កនៅតាមច្រកអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងបានត្រៀមបន្ទប់ដាក់អ្នកជំងឺឲ្យនៅដាច់ដោយឡែកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យខេត្តព្រះសីហនុ និងមន្ទីរពេទ្យខេត្តសៀមរាប ត្រៀមសម្ភារៈ បរិក្ខាពេទ្យ និងឱសថចាំបាច់សម្រាប់ការព្យាបាលផងដែរ។ ក្រសួងក៏បានផ្សព្វផ្សាយជូនដំណឹងដល់មន្ទីរពេទ្យជាតិ និងមន្ទីរសុខាភិបាលទាំង២៥រាជធានី-ខេត្ត ឲ្យត្រៀមលក្ខណៈជាស្រេច ក្នុងការឆ្លើយតប និងផ្តល់អន្តរាគមន៍ជាបន្ទាន់ប្រសិនបើមានករណីសង្ស័យ និងកំពុងពង្រឹងការងារតាមដានជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ និង បានពិនិត្យវាយតម្លៃរកលំនាំមិនធម្មតានៃជំងឺនេះជានិច្ច។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមគេហទំព័រ និងទំព័រហ្វេសប៊ុករបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសំភារៈអប់រំសុខភាពអំពីការបង្ការការឆ្លងជំងឺតាមផ្លូវដង្ហើម ដែលអាចទាញយកមកមើលបាន និងហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

សំរាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនង៖

ក្រសួងសុខាភិបាល
លោកវេជ្ជបណ្ឌិត លី សុវ៉ាន់ ៖ ០១២ ៨២៥ ៤២៤
លោកវេជ្ជបណ្ឌិត យី សេងឌឿន ៖ ០១២ ៤៨៨ ៩៨១
លោកស្រីវេជ្ជបណ្ឌិត គេង ស្រី ៖ ០១២ ៨៣៦ ៨៦៨

ថ្ងៃសុក្រ ១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០



វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ
និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា